**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀងស្តីពីការព្យួរកិច្ចសន្យាការងារ

ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០២៣ វេលាម៉ោង០៩:០០នាទី ក្នុងរោងចក្រផលិតស្បែកជើង អេ ផ្លាស់ អេ ស៊ូ ខេមបូឌា ខូអិលធីឌី បានចុះកិច្ចព្រមព្រៀងស្តីពីការព្យួរកិច្ចសន្យាការងារជាមួយតំណាងកម្មករ និងសហជីពពលកម្មកម្ពុជា សហជីពមោទនភាពកម្មករខ្មែរ សហជីពឯករាជ្យការពារកម្មករ សហជីពហត្ថកម្មករ សហជីពឯករាជ្យដើម្បីសេរីភាព សហជីពអភិវឌ្ឍន៍កម្មករ ប្រចាំមូលដ្ឋាន ប្រចាំរោងចក្រ អេផ្លាស់អេ ស៊ូ ខេមបូឌា ខូអិលធីឌី ដែលមានប្រការដូចខាងក្រោម ៖

ប្រការ១ : ព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ១២៥៥នាក់ (ស្រី៧៥៦នាក់) ក្នុងចំណោមកម្មករនិយោជិតសរុប ចំនួន ១២៩៩នាក់ (ស្រី៧៩១នាក់) រយៈពេល ៦១ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០២៣ រហូតដល់ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០២៣ ដោយ មូលហេតុក្រុមហ៊ុន គ្មានអ្នកបញ្ជាទិញ ។

ប្រការ២ : ក្នុងរយៈពេលព្យួរកិច្ចសន្យាការងារ ក្រុមហ៊ុនបានផ្តល់ប្រាក់ឧបត្ថម្ភជូនកម្មករនិយោជិតម្នាក់ៗចំនួន ៣០ដុល្លាអាមេរិច ក្នុងមួយខែ ក្នុងនោះ ៖

- ចំនួន ១៥ដុល្លាអាមេរិច សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ០៧ថ្ងៃ ដល់ ១៤ថ្ងៃ
- ចំនួន ៣០ដុល្លាអាមេរិច សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១៥ថ្ងៃ ដល់ ០១ខែ

ដោយព្រមព្រៀងបើកជូននៅថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០២៣។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង10:30នាទី នាព្រឹកថ្ងៃដដែលក្រោមបរិយាកាសយោគយល់និងភាពទទួលខុសត្រូវចំពោះមុខច្បាប់។

ថ្ងៃ ចន្ទ័ ១៣រោច ខែ ទុតិយសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

ភ្នំពេញថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០២៣

ភាគីតំណាងសហជីពមូលដ្ឋាន និងតំណាងកម្មករនិយោជិត

ចិន វុទ្ធី    គឿន ចន្ទី    តែ វេងស្រៀង    អួន ឌីណា

ចិ គង់    ត្រឹម ហ៊ីម    ឆន ស្រីមុំ    តេង មករា    សៀវ សាខេន

ពេជ្រ វិសាល    គឿន ចន្ថា    អ៊ុន អន    ម៉ន ម៉ៅ    ខៀវ សារី

ភាគីតំណាងក្រុមហ៊ុន

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន អេផ្លាស់អេស៊ូ (ខេមបូឌា) A PLUS A SHOES (CAMBODIA) Co., Ltd. KINGDOM OF CAMBODIA

YEH YUNTUNG